លេខ ៤៧ ចេញផ្សាយថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០២៥

# ព្រឹត្តិបត្រព័ត៌មានប្រចាំខែឧសភា ឆ្នាំ២០២៥

**និយ័តករបរធនបាលកិច្ច**
**គ្រប់គ្រង ត្រួតពិនិត្យ និងអភិវឌ្ឍវិស័យ**
**បរធនបាលកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា**

## មាតិកា


- កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)........ទំព័រទី១
- កិច្ចសម្ភាសសម្រាប់ការរៀបចំ "ការសិក្សាពីឧត្តមានុវត្តន៍ និងយន្តការសម្រាប់អនុវត្តអាណត្តិកិច្ចការវិនិយោគ ក្រោមក្របខណ្ឌមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព"........ទំព័រទី២
- កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)........ទំព័រទី២
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៥........ទំព័រទី២
- កិច្ចប្រជុំរវាង Lion Trust (Singapore) និង ន.ប.ធ........ទំព័រទី៣
- កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែមេសា និងទិសដៅការងារបន្ត........ទំព័រទី៣
- សិក្ខាសាលាស្តីពីការត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ........ទំព័រទី៣
- កិច្ចប្រជុំពិភាក្សាលើការធ្វើចំណាត់ថ្នាក់សវនកម្មក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពី ន.ប.ធ........ទំព័រទី៤
- កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"........ទំព័រទី៤
- កម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ២០២៥ លើប្រធានបទ "Fraud & Financial Crime Asia 2025 (FFC25)"........ទំព័រទី៥
- សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងវិស័យសន្តិសុខសង្គម ស្តីពី "អនុសាសន៍ទី១៣, ទី១៤, ទី១៥ និងទី១៦ និងលទ្ធផលជាក់ស្តែងទី៤"........ទំព័រទី៥
- សិក្ខាសាលាស្តីពី "បរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក" ទំព័រទី៥
- កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៤........ទំព័រទី៦
- សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"........ទំព័រទី៦
- សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"........ទំព័រទី៧
- សិក្ខាសាលាស្តីពី "សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"........ទំព័រទី៧
- សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"........ទំព័រទី៧
- កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា-ឧសភា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៥........ទំព័រទី៨
- សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី "កម្មវិបាកសវនកម្មនិងនិយ័តកម្មលើធុរកិច្ចនិងបញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ"........ទំព័រទី៨


## កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នាព្រឹកថ្ងៃសុក្រ ៦ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី២ ខែឧសភា គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយសហការី បានចូលរួមកិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យលើខ្លឹមសារនៃសេចក្តីព្រាង ចំនួន ២ រួមមាន៖ ១. សេចក្តីព្រាងផែនការសកម្មភាពសម្រាប់បីឆ្នាំរំកិល ២០២៥-២០២៧ របស់និយ័តករធានារ៉ាប់រងកម្ពុជា និង ២. សេចក្តីព្រាងប្រកាសស្តីពី ការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មទ្រព្យឪជីថល របស់និយ័តករមូលបត្រកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម រស់ សីលវ៉ា** អនុប្រធាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចសម្ភាសសម្រាប់ការរៀបចំ "ការសិក្សាពីឧត្តមានុវត្តន៍ និងយន្តការសម្រាប់អនុវត្តអាណត្តិកិច្ចការវិនិយោគ ក្រោមក្របខណ្ឌមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព"

នាព្រឹកថ្ងៃចន្ទ ៩ កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែឧសភា គ.ស. ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច អមដោយសហការី បានចូលរួមផ្តល់កិច្ចសម្ភាសសម្រាប់ការរៀបចំ "ការសិក្សាពីឧត្តមានុវត្តន៍ និងយន្តការសម្រាប់អនុវត្តអាណត្តិកិច្ចការវិនិយោគ ក្រោមក្របខណ្ឌមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព" ជាមួយក្រុមការងារលេខាធិការដ្ឋានមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព (**ម.អ.ស.**) និងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង (Agence Française de Développement - AFD)។ កិច្ចសម្ភាសនេះ មានគោលបំណងសំខាន់ ដើម្បីពិនិត្យ និងពិភាក្សាទៅលើរបាយការណ៍លទ្ធផលបឋមនៃការសិក្សាស្តីពីឧត្តមានុវត្តន៍ និងយន្តការសម្រាប់អនុវត្តអាណត្តិកិច្ចការវិនិយោគ ក្រោមក្របខណ្ឌ **ម.អ.ស.**។



រូបភាព៖ កិច្ចសម្ភាសសម្រាប់ការរៀបចំ "ការសិក្សាពីឧត្តមានុវត្តន៍ និងយន្តការសម្រាប់អនុវត្តអាណត្តិកិច្ចការវិនិយោគ ក្រោមក្របខណ្ឌមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព"។

## កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)

នារសៀលថ្ងៃចន្ទ ៩កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៥ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមដោយ**លោកស្រី ឈាន សុខារី** និងសហការី បានចូលរួមកិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (**អ.ស.ហ.**) ដើម្បីពិនិត្យពិភាក្សាលើខ្លឹមសារនៃសេចក្តីព្រាងប្រកាសស្តីពីការបោះផ្សាយលក់សញ្ញាបណ្ណហេដ្ឋារចនាសម្ព័ន្ធ របស់និយ័តករមូលបត្រកម្ពុជា ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមរយៈកិច្ចសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋាន **អ.ស.ហ.** តាមប្រព័ន្ធអនឡាញ (Zoom)។




រូបភាព៖ កិច្ចប្រជុំបច្ចេកទេសអន្តរនិយ័តករនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ (អ.ស.ហ.)។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៥

នាព្រឹកថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំម្សាញ់សប្តស័ក ព.ស. ២៥៦៨ត្រូវនឹងថ្ងៃទី៧ខែឧសភាគ.ស.២០២៥**ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៥ របស់នាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ចនៃនិយ័តករបរធនបាលកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកប្រធានស្តីទីនាយកដ្ឋាន, ប្រធានការិយាល័យ, អនុប្រធានការិយាល័យ និងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច។ នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមអគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមេសា ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋាន និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



រូបភាព៖ កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែឧសភា ឆ្នាំ២០២៥។

## កិច្ចប្រជុំរវាង Lion Trust (Singapore) និង ន.ប.ធ.

នារសៀលថ្ងៃពុធ ១១កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៧ ខែឧសភា ឆ្នាំ២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) អមអមដោយសហការី បានអញ្ជើញទទួលជួបប្រជុំជាមួយ **លោក-Ashley Ong នាយកប្រតិបត្តិ** និង**លោកស្រី Yvonne Lee នាយក-គ្រប់គ្រងផ្នែកនីតិកម្ម** របស់ក្រុមហ៊ុន Lion Trust (Singapore) Limited, **លោក គង់ ប៊ុននរិទ្ធ នាយកប្រតិបត្តិ** របស់ធនាគារ ស៊ីស៊ីយូ ខមមើសល ប៉ែង ម.ក និង**លោក Eric Loo** របស់ក្រុមហ៊ុន បេនចាប៉ាន អ៊ែសេត មេនេចម៉ិន(**ខេមបូឌា**) ម.ក ដើម្បីពិភាក្សាអំពីកាលានុវត្តភាពសម្រាប់ការវិនិយោគនៅកម្ពុជា និងស្វែងយល់អំពីការអភិវឌ្ឍទីផ្សារបរធនបាលកិច្ច ក៏ដូចជាគំនិតផ្តួចផ្តើមនានាដើម្បីអភិវឌ្ឍបរធនបាលកិច្ចគ្រួសារ ផងដែរ។



រូបភាព៖ កិច្ចប្រជុំរវាង Lion Trust (Singapore) និង ន.ប.ធ.។

## កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែមេសា និងទិសដៅការងារបន្ត

នាព្រឹកថ្ងៃព្រហស្បតិ៍ ១២កើតខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី៨ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែមេសា និងទិសដៅការងារបន្តរបស់នាយកដ្ឋានកិច្ចការទូទៅ។កិច្ចប្រជុំនេះ មានការចូលរួមពីប្រធាននាយកដ្ឋាន, អនុប្រធាននាយកដ្ឋាន, ប្រធានការិយាល័យ និងមន្ត្រីជំនាញនៃនាយកដ្ឋានកិច្ចការទូទៅទាំងអស់។

កិច្ចប្រជុំនេះត្រូវបានបញ្ចប់ប្រកបដោយផ្លែផ្កា និងស្មារតីមោះមុតក្នុងការបំពេញការងារតាមផែនការខែបន្ទាប់។



រូបភាព៖កិច្ចប្រជុំបូកសរុបសមិទ្ធផលការងារប្រចាំខែមេសា និងទិសដៅការងារបន្ត។

## សិក្ខាសាលាស្តីពីការត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាព្រឹកថ្ងៃសុក្រ ១៣កើតខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែឧសភា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាត និងចាត់តាំងពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ. លោក យុន វាសនា ប្រធាននាយកដ្ឋានកិច្ចការទូទៅ** អមដោយសហការី បានចូលរួមសិក្ខាសាលាស្តីពីការត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ** និងមានការអញ្ជើញចូលរួមពី ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាថ្នាក់ដឹកនាំស្ថាប័នអង្គភាពក្រោមឱវាទ នៅសណ្ឋាគារហ្គាឌិនស៊ីធី។



រូបភាព៖ សិក្ខាសាលាស្តីពីការត្រៀមលក្ខណៈសម្រាប់ការរៀបចំថវិកាឆ្នាំ២០២៦ ផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## កិច្ចប្រជុំពិភាក្សាលើការធ្វើចំណាត់ថ្នាក់សវនកម្មក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពី ន.ប.ធ.

នាព្រឹកថ្ងៃសុក្រ ១៣កើត ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៨ ត្រូវនឹងថ្ងៃទី៩ ខែឧសភា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **ឯកឧត្តម ណឹ សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយមន្ត្រីជំនាញ បានចូលរួមកិច្ចប្រជុំពិភាក្សាលើការធ្វើចំណាត់ថ្នាក់សវនកម្មក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពី **ន.ប.ធ.** ដែលចែកចេញជាប្រភេទក្រុមហ៊ុនទទួលខុសត្រូវជាសាធារណៈ និងក្រុមហ៊ុន មិនទទួលខុសត្រូវជាសាធារណៈ។ ក្នុងកិច្ចប្រជុំនេះ ត្រូវបានរៀបចំដោយនិយ័តករគណនេយ្យ និងសវនកម្ម និងមានការចូលរួមពី ថ្នាក់ដឹកនាំ និងតំណាងនិយ័តករជានាវ៉ាប់រងកម្ពុជា និងវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជាផងដែរ។



រូបភាព៖ កិច្ចប្រជុំពិភាក្សាលើការធ្វើចំណាត់ថ្នាក់សវនកម្មក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណពី ន.ប.ធ.។

## កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"

នៅថ្ងៃអង្គារ ២រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២៥ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **លោក រិន រដ្ឋា ប្រធានស្តីទីនៃនាយកដ្ឋានចុះបញ្ជីបរធនបាលកិច្ច** អមដោយ**លោក ឆែម លាភហេង អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច** បានដឹកនាំក្រុមការងារនៃ **ន.ប.ធ.** ចូលរួមកម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា" សម្រាប់ថ្នាក់ដឹកនាំ និងបុគ្គលិករបស់ក្រុមហ៊ុន ស៊ុន ណឹង ត្រាស់ ឯ.ក ដែលជាក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណក្រុមហ៊ុនបរធនបាលសម្រាប់ប្រតិបត្តិការបរធនបាលកិច្ចពាណិជ្ជកម្ម និងបរធនបាលកិច្ចបុគ្គលពី **ន.ប.ធ.**។ កម្មវិធីបណ្តុះបណ្តាលនេះ បានរៀបចំនៅទីស្នាក់ការរបស់ក្រុមហ៊ុន ស៊ុន ណឹង ត្រាស់ ឯ.ក ដោយមានការចូលរួមពីថ្នាក់ដឹកនាំ និងបុគ្គលិក។



រូបភាព៖ កម្មវិធីបណ្តុះបណ្តាលស្តីពី "យន្តការបរធនបាលកិច្ចនៅកម្ពុជា"។

## កម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ២០២៥ លើប្រធានបទ "Fraud & Financial Crime Asia 2025 (FFC25)"

នៅថ្ងៃព្រហស្បតិ៍ ៤រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៥ ខែឧសភា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) **កញ្ញា ឆែម គឹមហ៊ាង** និង **កញ្ញា ហ៊ឹម ដាណែត** មន្ត្រីនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច បានចូលរួមកម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ២០២៥ លើប្រធានបទ "Fraud & Financial Crime Asia 2025 (**FFC25**)" ក្នុងគោលបំណងដើម្បីសិក្សាឈ្វេងយល់ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មហិរញ្ញវត្ថុ, ការកើនឡើងពីការគំរាមកំហែងនៃឧក្រិដ្ឋកម្មហិរញ្ញវត្ថុ, សកម្មភាពសម្អាតប្រាក់, ការលួចអត្តសញ្ញាណ, ការលួចប្រាក់តាមអ៊ីនធឺណិត, ការបន្លំឯកសារហិរញ្ញវត្ថុ និងការត្រៀមខ្លួនទុកជាមុនក្នុងការបង្ការនិងទប់ស្កាត់ចំពោះឧក្រិដ្ឋកម្មហិរញ្ញវត្ថុ ឬសកម្មភាពខុសច្បាប់ និងហានិភ័យផ្សេងទៀតនៃការមិនអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិ។

កម្មវិធីបណ្តុះបណ្តាលនេះមានការអញ្ជើញចូលរួមពីតំណាងនៃបណ្តាប្រទេសផ្សេងៗ រួមមាន៖ ប្រទេសសិង្ហបុរី, ប្រទេសហុងកុង, ប្រទេសជប៉ុន, ប្រទេសអូស្ត្រាលី និងសហរដ្ឋអាមេរិក។ កម្មវិធីនេះត្រូវបានរៀបចំឡើងជារៀងរាល់ឆ្នាំនៅប្រទេសសិង្ហបុរី ដោយមាន ការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងតំណាងជាន់ខ្ពស់ប្រទេស និងស្ថាប័នពាក់ព័ន្ធនៅជុំវិញពិភពលោកដើម្បីចូលរួមចែករំលែកចំណេះដឹងក្នុងការបង្ការ, ការទប់ស្កាត់ចំពោះឧក្រិដ្ឋកម្មហិរញ្ញវត្ថុ និងសកម្មភាពលាងសម្អាតប្រាក់។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888




**រូបភាព៖** កម្មវិធីបណ្តុះបណ្តាលប្រចាំឆ្នាំ២០២៥ លើប្រធានបទ “Fraud & Financial Crime Asia 2025 ( FFC25 )” ។

## សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងវិស័យសន្តិសុខសង្គម ស្តីពី “អនុសាសន៍ទី១៣, ទី១៤, ទី១៥ និងទី១៦ និងលទ្ធផលជាក់ស្តែងទី៤”

នៅថ្ងៃចន្ទ ៨រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី១៩ ខែឧសភា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.**, **ឯកឧត្តម នន ពិសិដ្ឋ** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយ **លោក ឆែម លាបហេង អនុប្រធាននាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ ន.ប.ធ.** និងក្រុមការងារ បានចូលរួមក្នុងសិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងវិស័យសន្តិសុខសង្គម ស្តីពី “អនុសាសន៍ទី១៣, ទី១៤, ទី១៥ និងទី១៦ និងលទ្ធផលជាក់ស្តែងទី៤” របស់ក្រុមការងារហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ។ សិក្ខាសាលានេះក៏មានការអញ្ជើញចូលរួមធ្វើបទបង្ហាញពីគ្រូឧទ្ទេស និងមន្ត្រីជំនាញរបស់អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ព្រមទាំងបុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងវិស័យសន្តិសុខសង្គម ដែលមានសិក្ខាកាមសរុបចំនួន ៧៥ រូប។



**រូបភាព៖** សិក្ខាសាលាលើកកម្ពស់ការយល់ដឹងដល់បុគ្គលរាយការណ៍ក្នុងវិស័យបរធនបាលកិច្ច និងវិស័យសន្តិសុខសង្គម ស្តីពី “អនុសាសន៍ទី១៣, ទី១៤, ទី១៥ និងទី១៦ និងលទ្ធផលជាក់ស្តែងទី៤”។

## សិក្ខាសាលាស្តីពី “បរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក”

នារសៀល ថ្ងៃអង្គារ ៩រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២០ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម ឈី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** បានចូលរួមជាគណៈអធិបតីក្នុងសិក្ខាសាលាស្តីពី “បរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក” នៅទីស្នាក់ការគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលសហការរៀបចំដោយនិយ័តករបរធនបាលកិច្ច គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងធនាគារ ស្ថាបនា ភីអិលស៊ី។ សិក្ខាសាលានេះ រៀបចំឡើងក្នុងគោលបំណងបញ្ជ្រាបការយល់ដឹងឱ្យកាន់តែទូលំទូលាយដល់ថ្នាក់ដឹកនាំ និងសមាជិក/សមាជិការបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា វិនិយោគិន និងតួអង្គពាក់ព័ន្ធអំពីយន្តការបរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក, យន្តការបរធនបាលកិច្ច និងផលប្រយោជន៍ពាក់ព័ន្ធក្នុងការថែរក្សា និងការការពារទ្រព្យសម្បត្តិបរធនបាលកិច្ច ជាពិសេសដល់វិស័យឯកជន។



**រូបភាព៖** សិក្ខាសាលាស្តីពី “បរធនបាលកិច្ចសេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក”។

## កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៤

នៅព្រឹកថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច ( **ន.ប.ធ.** ) និងជាសមាជិកក្រុមប្រឹក្សាអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ ( **អ.ស.ហ.** ) បានអញ្ជើញចូលរួមកិច្ចប្រជុំក្រុមប្រឹក្សា **អ.ស.ហ.** អាណត្តិទី១ លើកទី២៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី **រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានក្រុមប្រឹក្សា អ.ស.ហ.** នៅទីស្តីការ **អ.ស.ហ.**។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888



រូបភាព៖ កិច្ចប្រជុំក្រុមប្រឹក្សា អ.ស.ហ. អាណត្តិទី១ លើកទី២៤។

## សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬ សេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"

នាព្រឹកថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែឧសភា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យបៀលប្រាយ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម នង ពិសិដ្ឋ** អគ្គនាយករង នៃនិយ័តករបរធនបាលកិច្ច និង **លោកបណ្ឌិត ឌី ដាវុឌ្ឍ សាកលវិទ្យាធិការរងជាន់ខ្ពស់នៃសាកលវិទ្យាល័យបៀលប្រាយ** នៅសាកលវិទ្យាល័យបៀលប្រាយ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ និងគុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, **លោក ស៊ីយ៉ា ម៉ាលីដា នាយកការិយាល័យប្រតិបត្តិការមូលបត្រនិង បរធនបាលកិច្ច** វាគ្មិនតំណាងពីធនាគារអេស៊ីលីដា ភីអិលស៊ី, ថ្នាក់ដឹកនាំ, សាស្ត្រាចារ្យ, និងនិស្សិតនៃសាកលវិទ្យាល័យបៀលប្រាយ។



រូបភាព៖ សិក្ខាសាលាស្តីពី "ប្រតិបត្តិការសម្រាប់សេវារក្សាសុវត្ថិភាព ឬសេវារក្សាទុក (Escrow Services) ក្នុងវិស័យបរធនបាលកិច្ច"។

## សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"

នៅថ្ងៃពុធ ១០រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២១ ខែឧសភា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) ដែលជាអង្គភាពអនុវត្តគម្រោងប្រកួតប្រជែងខ្សែច្រវាក់តម្លៃ និងការលើកកម្ពស់សុវត្ថិភាពកសិកម្ម សមាសភាគទី១ (ACSEP-PIU1) ក្នុងក្របខណ្ឌក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានរៀបចំសិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP" ក្រោមការដឹកនាំរបស់ **លោក ប៉ូ សំអាង ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការនៃ ន.ប.ធ.** និងជាប្រធានផ្នែកប្រតិបត្តិការនៃគម្រោង ACSEP-PIU1 តំណាងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃ **ន.ប.ធ.** និងជាប្រធានគ្រប់គ្រងគម្រោង ACSEP-PIU1។

កម្មវិធីនេះ ត្រូវបានរៀបចំឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីសារៈតារ និងបច្ចុប្បន្នភាពនៃគម្រោង ACSEP ជាពិសេសគោលនយោបាយឥណទាន បែបបទ និងនីតិវិធីក្នុងការរៀបចំស្នើសុំឥណទាននៃគម្រោង ACSEP ដែលជាឥណទានមានលក្ខខណ្ឌអនុគ្រោះ និងគាំទ្រដល់សហគមន៍កសិកម្ម និងកសិធុកិច្ច ដល់សមាជិក-សមាជិកាសហគមន៍កសិកម្ម សាគ្រាមអមតៈ និងព្រៃម្រ៉ុក្តីសង្ឃឹម ដែលស្ថិតនៅឃុំសាគ្រាម និងឃុំផាន់ញើម ស្រុកប្រាសាទ ខេត្តកំពង់ធំ ដែលមានបំណងស្វែងរកហិរញ្ញប្បទាន ដើម្បីគាំទ្រ និងពង្រីកផែនការអាជីវកម្មរបស់ខ្លួន។

សិក្ខាសាលានេះ មានការចូលរួមដោយ សមាជិក/សមាជិកាសហគមន៍កសិកម្ម, មន្ត្រី និងទីប្រឹក្សារបស់ ACSEP-PIU1, តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, តំណាងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តកំពង់ធំ, និងក្រុមការងារគម្រោងមកពីស្ថាប័នហិរញ្ញវត្ថុដៃគូទាំងពីរ រួមមាន៖ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម (ARDB) និងធនាគារស្ថាបនា (Sathapana Bank)។



រូបភាព៖ សិក្ខាសាលាស្តីពី "ការផ្សព្វផ្សាយផលិតផលឥណទានគម្រោង ACSEP"។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888

## សិក្ខាសាលាស្តីពី "សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"

នាថ្ងៃព្រហស្បតិ៍ ១១រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែឧសភា គ.ស.២០២៥ ដោយទទួលបានការអនុញ្ញាត និងចាត់តាំងរបស់ **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **លោក សារី ពុធរង្សី** អនុប្រធានការិយាល័យនីតិកម្មនៃនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ចនៃ **ន.ប.ធ.** បានអញ្ជើញចូលរួមជាវាគ្មិនក្នុង "សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ" ដែលរៀបចំដោយអគ្គលេខាធិការដ្ឋាននៃ **អ.ស.ហ.** និងមានការចូលរួមពីតំណាងនិយ័តករ និងអង្គភាពក្រោមឱវាទរបស់ **អ.ស.ហ.**, រដ្ឋបាលខេត្តក្រចេះ, សាខាពន្ធដារខេត្តក្រចេះ, ស្នងការដ្ឋាននគរបាលខេត្តក្រចេះ ព្រមទាំងសិស្សនិស្សិតនៃសាកលវិទ្យាល័យនៃខេត្តក្រចេះ និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៅសណ្ឋាគារ ហ៊ារប៊ុន្នី នៅខេត្តក្រចេះ។



រូបភាព៖ សិក្ខាសាលាស្តីពី "សិក្ខាសាលាផ្សព្វផ្សាយច្បាប់ និងបទប្បញ្ញត្តិរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ"។

## សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"

នារសៀលថ្ងៃសៅរ៍ ១៣រោច ខែពិសាខ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៤ ខែឧសភា គ.ស.២០២៥ និយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) និងសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តកំពង់ធំ បានសហការគ្នារៀបចំសិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា" ក្រោមអធិបតីភាពរបស់ **ឯកឧត្តម ណឺ សារាល** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច និង **លោក តាក កាក់នីកា នាយកសាខានៃសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា** នៅសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តកំពង់ធំ។

សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលដៅបញ្ជ្រាបការយល់ដឹងជាសាធារណៈឱ្យបានកាន់តែទូលំទូលាយ និងស៊ីជម្រៅសម្រាប់និស្សិតនៅសាកលវិទ្យាល័យ អំពីយន្តការប្រតិបត្តិការបរធនបាលកិច្ច បទដ្ឋានគតិយុត្តពាក់ព័ន្ធ គុណប្រយោជន៍នៃវិស័យបរធនបាលកិច្ច។ សិក្ខាសាលានេះក៏បានផ្តល់ឱកាសដល់និស្សិតដើម្បីធ្វើការបង្កើនចំណេះដឹងបន្ថែមពាក់ព័ន្ធវិស័យហិរញ្ញវត្ថុមិនមែនធនាគារផងដែរ។ កម្មវិធីនេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់នៃ **ន.ប.ធ.** និងមន្ត្រីជំនាញ, សាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យ ឯកទេស នៃកម្ពុជា ខេត្តកំពង់ធំ។



រូបភាព៖ សិក្ខាសាលាស្តីពី "ការឈ្វេងយល់ពីកិច្ចដំណើរការអភិវឌ្ឍន៍វិស័យបរធនបាលកិច្ចនៅព្រះរាជាណាចក្រកម្ពុជា"។

## កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា-ឧសភា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៥

នាព្រឹកថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា គ.ស.២០២៥ **ឯកឧត្តម នខ ពិសិដ្ឋ** អគ្គនាយករងនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**) បានដឹកនាំកិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា-ឧសភា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៥ ក្នុងកម្រិតអន្តរនាយកដ្ឋាន រួមមាន នាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល និងសហប្រតិបត្តិការ និងនាយកដ្ឋានកិច្ចការគតិយុត្តនិងអធិការកិច្ច។ កិច្ចប្រជុំនេះ មានការចូលរួមពីលោកប្រធាននាយកដ្ឋាន, ប្រធាននាយកដ្ឋានស្តីទី, ប្រធានការិយាល័យ, អនុប្រធានការិយាល័យនិងមន្ត្រីជំនាញទាំងអស់នៃនាយកដ្ឋានទាំងពីរ។ នៅក្នុងកិច្ចប្រជុំនេះ **ឯកឧត្តមអគ្គនាយករង** បានធ្វើការវាយតម្លៃខ្ពស់លើសមិទ្ធផលការងារដែលសម្រេចបានក្នុងខែមេសា-ឧសភា ឆ្នាំ២០២៥ ព្រមទាំងបានកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់របស់ថ្នាក់ដឹកនាំ និងមន្ត្រីទាំងអស់នៃនាយកដ្ឋានទាំងពីរ និងបានផ្តល់ជាអនុសាសន៍ណែនាំសម្រាប់ទិសដៅការងារនៅក្នុងខែបន្ទាប់ផងដែរ។ កិច្ចប្រជុំនេះ បានបញ្ចប់ដោយរលូន ប្រកបដោយផ្លែផ្កា និងស្មារតីទទួលខុសត្រូវខ្ពស់។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888





**រូបភាព៖** កិច្ចប្រជុំបូកសរុបការងារប្រចាំខែមេសា-ឧសភា ឆ្នាំ២០២៥ និងទិសដៅការងារប្រចាំខែមិថុនា ឆ្នាំ២០២៥។

## សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី "កម្មវិបាកសវនកម្មនិងនិយ័ត-កម្មលើធុរកិច្ច និងបញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ"

នារសៀលថ្ងៃព្រហស្បតិ៍ ៣កើត ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា គ.ស.២០២៥, ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តម សុខ ដារ៉ា** អគ្គនាយកនៃនិយ័តករបរធនបាលកិច្ច (**ន.ប.ធ.**), **ឯកឧត្តម ណី សាគល** អគ្គនាយករងនៃ **ន.ប.ធ.** អមដោយសហការី បានអញ្ជើញចូលរួមសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី "កម្មវិបាកសវនកម្មនិងនិយ័ត-កម្មលើធុរកិច្ច និងបញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ" ក្រោមអធិបតី-ភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **អ.ស.ហ.**។ សិក្ខាសាលានេះ មានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំ និងមន្ត្រីនៃនិយ័តករ និងអង្គភាពក្រោមឱវាទ **អ.ស.ហ.**។






**រូបភាព៖** សិក្ខាសាលាចែករំលែកចំណេះដឹងស្តីពី "កម្មវិបាកសវនកម្មនិងនិយ័ត-កម្មលើធុរកិច្ច និងបញ្ញាសិប្បនិម្មិតក្នុងវិស័យហិរញ្ញវត្ថុ" ។



អគារ ១៦៨F ជាន់ទី៨ ផ្លូវ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ | Building 168F, 8th Floor, Street 598, Sangkat Chrang Chamres 1, Phnom Penh
www.trustregulator.gov.kh www.facebook.com/trustregulatorcambodia (855) 23 237 888